សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

ROYAL UNIVERSITY OF LAW AND ECONOMIC

## កិច្ចការស្រាវជ្រាវ

# កម្មសិទ្ធិបញ្ញា

លោកស្រីសាស្ត្រាចារ្យ ៖ ព្រុំ ទេវី

ស្រាវជ្រាវដោយនិស្សិតក្រុមទី ៦

ឈ្មោះ: ១. ឡាយ បញ្ញាពេជ្រ
២. ឆី កង
៣. ឆុំ សុគន្ធី
៤. ទ្រី ណៃខ្សៀឌឹម
៥. ស៊ីន ថាវី
៦. លី លក្ខិណា

មុខវិជ្ជា ៖ វិធីសាស្ត្រស្រាវជ្រាវ

ជំនាញ នីតិសាស្ត្រ

ថ្នាក់ បរិញ្ញាបត្រ នីតិសាស្ត្រL2B01 ឆ្នាំសិក្សា២០២៥-២០២៦ ឆ្នាំទី២

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំទាំងអស់គ្នា ដែលជានិស្សិតថ្នាក់បរិញ្ញាប័ត្រនៃសាលកវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមសំដែងនូវកតញ្ញូតាធម៌ និងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតៈ

លោកឪពុកអ្នកម្តាយ ដែលបានផ្តល់កំណើតដល់រូបកូន ព្រមទាំងលះបង់កម្លាំងកាយចិត្ត ចញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មានប្រៀនប្រដៅ ទំនុកបម្រុងដល់រូបកូនៗទាំងស្មារតី និង សម្ភារៈ ដើម្បីឲ្យកូនក្លាយជាកូនល្អ។ បន្ថែមពីនេះលោកទាំងបានខិតខំប្រឹងប្រែងជម្រុញឲ្យកូនបាន សិក្សារៀនសូត្រ ចាប់យកនូវចំណេះដឹងពី លោកគ្រូ និងអ្នកគ្រូ ចាប់តាំងពីថ្នាក់បឋមសិក្សា រហូតដល់ថ្នាក់បរិញ្ញាបត្រនៃឧត្តមសិក្សាសាលាដ៏ល្អមួយនេះ។ ចំពោះគុណូបការៈដ៏ថ្លាថ្លៃ គឺ គ្មានអ្វីប្រៀបផ្ទឹមបានឡើយ។ កូនគ្មានអ្វីក្រៅអំពី ការខិតខំក្រេបយកនូវចំណេះវិជ្ជាទាំងពួង ពី សំណាក់លោកគ្រូ និងអ្នកគ្រូដែលបានលះបង់ និងផ្តល់នូវពុទ្ធិដែលជាទ្រព្យមិនអាចកាត់ថ្លៃក្នុង លោកិយសច្ចៈយើងនេះ សម្រាប់ជាបញ្ញាណសម្រាប់ការកសាងស្ថានទៅថ្ងៃអនាគត ឲ្យបាន ថ្លៃថ្នូរ និងជាសសរទ្រូងនៃខ្លួនឯង គ្រួសារ និងសង្គមជាតិ។

លោកសាស្ត្រាចារ្យបណ្ឌិត ព្រុំ ទេវី ដែលលោកបានចំណាយពេលវេលាដ៏មមាញឹកលះបង់នូវ កំលាំងកាយ កំលាំងចិត្ត ក្នុងការជួយជ្រោមជ្រែង និងដឹកនាំសរសេរនូវរបាយការណ៍ ស្រាវជ្រាវនេះ តាំងពីចាប់ផ្តើមរហូតដល់ទីបញ្ចប់និងសំរេចបានជាស្ថាពរ។ លោកសាកលវិទ្យាធិការ លោកសាកលវិទ្យាករងព្រមទាំងសាស្ត្រាចារ្យ បណ្ឌិតនិង អនុបណ្ឌិតទាំងអស់នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ ដែលបានផ្តល់ចំណេះវិជ្ជា ណែនាំអប់រំដល់ យើងខ្ញុំអោយក្លា យជានិស្សិតម្នាក់ប្រកបដោយចំណេះដឹង ចំណេះធ្វើបានជ្រៅជ្រះខ្ពង់ខ្ពស់ សក្តិសម ដើម្បីបន្តវេនក្នុងការ អភិវឌ្ឍន៍ប្រទេសអោយចំរើនរុងរឿងដូចបណ្តាប្រទេសនៅលើសកលលោក។

សូមគោរពជូនពរ សម្តេច ឯកឧត្តម្ភ លោកជំទាវ អស់លោក លោកស្រី ជួបប្រទះតែសេចក្តីសុខនឹងពុទ្ធពរទាំងប្រាំប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ បដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ ។

# កិច្ចការស្រាវជ្រាវ

**១. ប្រធានបទបណ្តោះអាសន្ន៖** កម្មសិទ្ធិបញ្ញា

**២. ចំណោទបញ្ហាសំខាន់៖**

- អ្វីទៅជាកម្មសិទ្ធិបញ្ញា ?

**៣. ចំណោទបញ្ហាបន្ទាប់បន្សំ៖**

១. តើកម្មសិទ្ធិបញ្ញាមានប៉ុន្មានប្រភេទ ?

២. តើណាខ្លះស្នាដៃដែលទទួលបានកិច្ចការពារពីកម្មសិទ្ធិបញ្ញា ?

៣. បើមានភស្តុតាងគ្រប់គ្រាន់ តើជនដែលរំលោភកម្មសិទ្ធិបញ្ញានឹងទទួលការពិន័យយ៉ាងដូចម្តេច ?

**៤. កំណត់គោលដៅនៃការស្រាវជ្រាវ**

១. ស្វែងយល់ពីអត្ថន័យនិងប្រភេទនៃកម្មសិទ្ធិបញ្ញា

២. សិក្សាអំពីប្រភេទស្នាដៃដែលទទួលបានកិច្ចការពារ

៣. វិភាគអំពីវិធានការ និងការពិន័យចំពោះជនរំលោភកម្មសិទ្ធិបញ្ញា

**៥. កំណត់អថេរ**

១. អថេរមិនអាស្រ័យ(ហេតុ)៖ ការខ្វះចំណេះដឹងអំពីច្បាប់កម្មសិទ្ធិបញ្ញា

២. អថេរអាស្រ័យ(ផល)៖ ការប៉ះពាល់សិទ្ធិ និងផលប្រយោជន៍របស់ម្ចាស់ស្នាដៃ

៣. អថេរខាងក្រៅ (ប្រយោល)៖ កម្រិតនៃការយល់ដឹងរបស់សង្គមអំពីកម្មសិទ្ធិបញ្ញា

៤. អថេរអន្តរាគមន៍ (ផ្ទាល់)៖ ច្បាប់ និងបទបញ្ញត្តិពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញា

**៦. កំណត់គោលដៅប្រមូលទិន្នន័យ**

- តំបន់គោលដៅសម្រាប់ការប្រមូលទិន្នន័យ

- សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច
- បណ្ណាល័យ
- ស្ថាប័នដែលពាក់ព័ន្ធ

ក) ទិន្នន័យដែលមានស្រាប់

- សៀវភៅ និងឯកសារសិក្សាពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញា
- ច្បាប់ស្តីពីកម្មសិទ្ធិបញ្ញា
- អត្ថបទស្រាវជ្រាវ ឬគេហទំព័រផ្លូវការ

ខ) ទិន្នន័យបឋម

- ការសម្ភាសន៍
- ការស្ទង់មតិ
- ការសង្កេត

❖ ក្រុមគោលដៅ សម្រាប់ការប្រមូលទិន្នន័យបឋម

- និស្សិត
- គ្រូបង្រៀន
- មន្រ្តី ឬអ្នកជំនាញផ្នែកច្បាប់កម្មសិទ្ធិបញ្ញា

## ៧. មាតិកាបណ្ដោះអាសន្ន

សេចក្តីផ្តើម ........................................ ១

ជំពូកទី១ សញ្ញាណទូទៅនៃកម្មសិទ្ធិបញ្ញា ........................................ ២

១.១. និយមន័យ ........................................ ២

១.២. ប្រភេទនៃកម្មសិទ្ធិបញ្ញា ........................................ ២

១.២.១. កម្មសិទ្ធិឧស្សាហកម្ម ........................................ ៣

១.២.២. សិទ្ធិអ្នកនិពន្ធ ........................................ ៣

ជំពូកទី២ ប្រភេទនៃស្នាដៃដែលទទួលបានកិច្ចការពារ ........ ៤

២.១.ស្នាដៃអ្នកនិពន្ធសំដៅ ........ ៤

២.២.ស្នាដៃអ្នកសម្តែងសំដៅ ........ ៤

២.៣.ហ្វូណូក្រាមសំដៅ ........ ៤

២.៤.ការផ្សាយតាមទូរផ្សាយសំដៅ ........ ៤

ជំពូកទី៣ វិធានការនៃអំពើល្មើសចំពោះកម្មសិទ្ធិបញ្ញា ........ ៦

៣.១. សារៈសំខាន់នៃការពង្រឹងការការពារកម្មសិទ្ធិបញ្ញា ........ ៦

៣.២. និតិវិធីជាធរមាននៃការពង្រឹងការការពារកម្មសិទ្ធិបញ្ញា ........ ៧

៣.៣. ពង្រឹងការការពារកម្មសិទ្ធិបញ្ញា ........ ៨

៣.៤. ការអនុវត្តន៍ច្បាប់ កាតព្វកិច្ចទូទៅនៅប្រទេសកម្ពុជា ........ ៩

៣.៤.១. នីតិវិធីរដ្ឋប្បវេណី របស់តុលាការ និង ឧបបាស្រ័យ ........ ១០

៣.៤.២. វិធានការបណ្តោះអាសន្ន ........ ១១

៣.៤.៣. នីតិវិធីរដ្ឋបាល និង ឧបប្រាស្រ័យ ........ ១១

៣.៤.៤. វិធានការពិសេស តាមច្រកព្រំដែន ........ ១២

៣.៤.៥. នីតិវិធីព្រហ្មទ័ណ្ឌ ........ ១៣

សេចក្តីសន្និដ្ឋាន ........ ១៤

គន្ថិទ្ទេស ........ ១៥

# សេចក្ដីផ្ដើម

បណ្ដាប្រទេសនៅលើពិភពលោក តែងតែមានកត្តាជំរុញដោយពឹងផ្អែកទៅលើវិស័យឯកជន ព្រោះវាជាយានមួយសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ការយកចិត្តទុកដាក់ចំពោះវិស័យនេះ ធ្វើឱ្យប្រទេសអភិវឌ្ឍន៍ជាច្រើនបានចូលខ្លួនជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ហើយប្រកាន់យកប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី។ មូលហេតុដែលប្រទេសជាច្រើននៅលើពិភពលោកបង្កើតបទដ្ឋានផ្សេងៗដែលទាក់ទងទៅនឹងកម្មសិទ្ធិបញ្ញា គឺដើម្បីផ្ដល់នូវសីលធម៌ក្នុងការប្រកួតប្រជែងក្នុងវិស័យ ពាណិជ្ជកម្មដោយស្មោះត្រង់។

ជាក់ស្ដែងនៅក្នុងប្រទេសកម្ពុជាយើង រាជរដ្ឋាភិបាលក៏បានខិតខំប្រឹងប្រែងយ៉ាងខ្លាំងដើម្បីបញ្ជ្រាបវិស័យពាណិជ្ជកម្មទៅក្នុងគោលនយោបាយរបស់ជាតិ ដើម្បីជំរុញឱ្យមានកំណើនសេដ្ឋកិច្ចជាតិផងដែរ។ ដើម្បីបញ្ជ្រាបវិស័យនេះ ប្រកបដោយប្រសិទ្ធិភាពខ្ពស់ ជាក់ស្ដែងកម្ពុជាត្រូវបង្កើតនិងបង្កើនទំនាក់ទំនងរវាងវិស័យពាណិជ្ជកម្ម និងគោលនយោបាយជាតិឱ្យមានភាពច្បាស់លាស់ ដើម្បីទាក់ទាញអ្នកវិនិយោគបរទេស និងអ្នកវិនិយោគក្នុងស្រុក។

ទោះបីជាប្រទេសកម្ពុជាពឹងផ្អែកទៅលើវិស័យកម្មសិទ្ធិបញ្ញាចំពោះចំណូលសេដ្ឋកិច្ចជាតិក៏ ដូចជាសេដ្ឋកិច្ចរបស់បុគ្គលឯកជនក្ដី សព្វថ្ងៃនេះបុគ្គលមួយចំនួនហាក់ដូចជានៅមិនទាន់យល់ ច្បាស់អំពីការអនុវត្តនៃច្បាប់កម្មសិទ្ធិបញ្ញានៅឡើយ។ ដើម្បីធានាបាននូវការប្រកួតប្រជែងទៀងត្រង់ ក៏ដូចជាការការពារស្នាដៃរបស់ម្ចាស់សិទ្ធិ ការយល់ដឹងឱ្យកាន់ច្បាស់ពីច្បាប់កម្មសិទ្ធិបញ្ញាជាពិសេសច្បាប់ស្ដីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ និងច្បាប់ស្ដីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ពិតជាមានសារៈសំខាន់ណាស់សម្រាប់បុគ្គលដែលពាក់ព័ន្ធ ដើម្បីការពារប្រយោជន៍ខាងលើ និងអភិរក្សនូវសមិទ្ធផលដែលកើតចេញពីគំនិតបញ្ញារបស់ខ្លួន។ ដូច្នេះយោងតាមខ្លឹមសារខាងលើ ការយល់ដឹងអំពីអត្ថន័យនិងប្រភេទនៃ ច្បាប់កម្មសិទ្ធិបញ្ញាបានផ្ដល់ប្រយោជន៍ចំពោះម្ចាស់សិទ្ធិ ថាតើពួកគាត់នឹងទទួលបានការការពារអ្វីខ្លះក្នុងករណីដែលមានការរំលោភបំពានទៅ លើស្នាដៃរបស់ពួកគាត់ ក៏ដូចជានៅពេលដែលមានអំពើនោះកើតឡើង តើច្បាប់កម្មសិទ្ធិបញ្ញាមាន វិធានការយ៉ាងដូចម្ដេច។

# ជំពូកទី១ សញ្ញាណទូទៅនៃកម្មសិទ្ធិបញ្ញា

## ១.១. និយមន័យ

កម្មសិទ្ធិបញ្ញា ជាពាក្យពេជន៍គតិយុត្តដែលសំដៅដល់កម្មសិទ្ធិឧស្សាហកម្ម និងសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ។ កម្មសិទ្ធិ បញ្ញារួមមានការការពារប្រកាសនីយបត្រតក្កកម្ម ពាណិជ្ជកម្មសញ្ញា គំនូរឧស្សាហកម្ម និង កំណត់សំគាល់ប្រភពភូមិសាស្ត្រ ។ កម្មសិទ្ធិ បញ្ញារួមមានផងដែរនូវការការពារម៉ូតដែលមានអត្ថប្រយោជន៍ គំរូដែលមានប្រយោជន៍) រូបសណ្ឋានពាណិជ្ជកម្ម និងគំរូសបំព្រួញ ឬចំណុច ក្រាហ្វិកនៃសៀគ្វីរួម ដែលការការពារទាំងនេះមានអត្ថិភាព និង បានត្រូវការពារប្រឆាំងទល់នឹងការក្រកួតប្រជែងមិនស្មោះ ត្រង់រួមទាំងការការពារព័ត៌មានសម្ងាត់ ឬ ព័ត៌មានសំងាត់ផ្នែកពាណិជ្ជកម្មផងដែរ ។ កម្មសិទ្ធិបញ្ញាគឺជាប្រភេទកម្មសិទ្ធិមួយ ឫទ្រព្យ សម្បត្តិមួយបែបដែលមានតម្លៃ (បូមានតំលៃច្រើនជាងនេះទៀត) ជាងទ្រព្យសម្បត្តិជាអចលនៈទ្រព្យ ឬ ទ្រព្យសម្បត្តិដែលមានរូបរាង នានាសូម្បីតែទ្រព្យសម្បត្តិនេះអាចបិតក្នុងលក្ខណៈអរូបី ពុំអាចមើលឃើញ ដូចជាចំណេះដឹងជាដើម ។ តំលៃលៃទ្រព្យសម្បត្តិខាង បញ្ញាញាណទាក់ទងទៅនឹងទ្រព្យសម្បត្តិជារូបវ័ន្តបានកើនឡើងដោយសារតែសារៈ សំខាន់នៃបច្ចេកវិជ្ជា និងស្នាដៃបង្កើតថ្មីទាំងឡាយនៅ ក្នុងសង្គមសេដ្ឋកិច្ចទំនើបរបស់យើងនេះ ។ កម្មសិទ្ធិបញ្ញារួមមាន គំនិតថ្មីៗ ការសំដែងគំនិតដើម ឈ្មោះដែលមានលក្ខណៈលេចធ្លោ ដាច់ដោយឡែក នឹងរូបរាងខាងក្រៅដែលអាចធ្វើអោយផលិតផលមួយមានតំលៃនិងមានលក្ខណៈខុសប្លែកពីផលិតផលដទៃ។ កម្មសិទ្ធិបញ្ញាតែងតែត្រូវបានយកទៅប្រើប្រាស់ជាលក្ខណៈពាណិជ្ជកម្ម (ឬ ការ" ផ្តល់អាជ្ញាប័ណ្ណ") ក្នុងការប្រើប្រាស់សិទ្ធិរបស់ខ្លួនផ្ទាល់ ដោយគ្មានពាក់ព័ន្ធ នឹងកាធ្វើជំនួញចំពោះតំលៃដែលមានស្រាប់នៅក្នុងផលិតផល ឬ សេវាតាមរយៈមធ្យោបាយនៃប្រកាសនីយប័ត្រ តក្កកម្ម ឬ អាជ្ញាប័ណ្ណកម្មសិទ្ធិបញ្ញាដទៃទៀតដែលផ្ទេរសិទ្ធិពីម្ចាស់កម្មសិទ្ធិ ម្នាក់ទៅអោយអ្នកទទួលសិទ្ធិម្នាក់ទៀត ។

## ១.២. ប្រភេទនៃកម្មសិទ្ធិបញ្ញា

កម្មសិទ្ធិបញ្ញា ត្រូវបានបែងចែកជាពីរប្រភេទគឺកម្មសិទ្ធិឧស្សាហកម្ម សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល។ ច្បាប់ស្តីពីកម្មសិទ្ធិបញ្ញាមានលក្ខណៈខុសៗគ្នាដូចជា ភាពខុសគ្នាទៅតាមប្រភេទកម្មសិទ្ធិបញ្ញា ភាពខុសគ្នាទៅតាមច្បាប់ក្នុងប្រទេសនីមួយៗ និងភាពខុសគ្នាទៅតាមច្បាប់ក្នុងតំបន់ និងច្បាប់អន្តរជាតិជាដើម។

### ១.២.១. កម្មសិទ្ធិឧស្សាហកម្ម

កម្មសិទ្ធិឧស្សាហកម្មរួមមាន ប្រកាសនីយបត្រតក្កកម្ម ម៉ាក គំនូរឧស្សាហកម្ម និងម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ។

### ១.២.២. សិទ្ធិអ្នកនិពន្ធ

សិទ្ធិអ្នកនិពន្ធជាសិទ្ធិដែលផ្តល់ឱ្យដោយច្បាប់ដល់អ្នកនិពន្ធ សិល្បៈករឬអ្នកបង្កើតស្នាដៃ ផ្សេងៗទៀត ក្នុងការប្រើប្រាស់និងការពារស្នាដៃរបស់ខ្លួន រួមមានស្នាដៃ អក្សរសាស្ត្រ និងសិល្បៈទាំងឡាយដូចជារឿងប្រលោមលោក កំណាព្យ ល្ខោន ភាពយន្ត ស្នាដៃតន្ត្រី គំនូរ រូបថត ចម្លាក់ និងស្ថាបត្យកម្មជាដើម។ សិទ្ធិប្រហាក់ប្រហែល គឺផ្សារភ្ជាប់ជាមួយនឹងសិទ្ធិអ្នកនិពន្ធ ដែលសំដៅទៅលើសិទ្ធិរបស់អ្នកសម្តែង ផលិតករហ្វូណូក្រាម និងអង្គភាពផ្សាព្វផ្សាយ។ ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែលមានគោលបំណងជានាការគោរពសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល និងការពារនូវផលិតផល វប្បធម៌ជាស្នាដៃ អ្នកនិពន្ធ អ្នកសម្តែង ផលិតករហ្វូណូក្រាម និងអង្គភាពទូរផ្សាយ សំដៅធានាការធ្វើអាជីវកម្មមួយត្រឹមត្រូវស្របច្បាប់លើផលិតផលវប្បធម៌ទាំងនេះ ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍន៍វិស័យវប្បធម៌។

# ជំពូកទី២ ប្រភេទនៃស្នាដៃដែលទទួលបានកិច្ចការពារ

ស្នាដៃដែលទទួលបានកិច្ចការពារមាន៤ ដូចជា៖

## ២.១.ស្នាដៃអ្នកនិពន្ធសំដៅ

ស្នាដៃអ្នកនិពន្ធសំដៅ ជាស្នាដៃនិពន្ធដោយជនជាតិខ្មែរ មានទីតាំងការិយាល័យនៅកម្ពុជា, ស្នាដៃដែលបោះពុម្ពដំបូងនៅកម្ពុជា ឬ បោះពុម្ពផ្សាយដំបូងនៅបរទេស ហើយយកមកបោះពុម្ពនៅកម្ពុជាកំឡុងពេល៣០ថ្ងៃ។ ស្នាដៃស្ថាបត្យកម្មដែលសាងសង់នៅកម្ពុជា ឬ សិល្បៈដែលជាប់រចនាសម្ព័ន្ធនៅកម្ពុជា។ ចុងក្រោយ ជាស្នាដៃដែលការពារដោយសន្ធិសញ្ញាអន្តរជាតិ។

## ២.២.ស្នាដៃអ្នកសម្តែងសំដៅ

ស្នាដៃអ្នកសម្តែងសំដៅ ជាស្នាដៃអ្នកសម្តែងជាជនជាតិខ្មែរ។ បើអ្នកសម្តែងមិនមែនជនជាតិខ្មែរ តែការសម្តែងនោះបានសម្តែងនៅកម្ពុជា ថតបញ្ចូលហ្វូណូក្រាមដែលស្ថិតក្រោមការការពារនៃច្បាប់។ បើមិនទាន់បានថតបញ្ចូលជាហ្វូណូក្រាមទេ តែបានផ្សាយតាមទូរផ្សាយដែលស្ថិតក្រោមការពារនៃច្បាប់។

## ២.៣.ហ្វូណូក្រាមសំដៅ

ហ្វូណូក្រាមសំដៅ ជាហ្វូណូក្រាមរបស់ផលិតករដែលមានសញ្ជាតិខ្មែរ, ថតបញ្ចូលសំឡេងលើកដំបូងនៅកម្ពុជា, និងបានថតផ្សាយដំបូងនៅកម្ពុជា។

## ២.៤.ការផ្សាយតាមទូរផ្សាយសំដៅ

ការផ្សាយតាមទូរផ្សាយសំដៅ ជាការផ្សាយនៃអង្គភាពដែលមានទីស្នាក់ការនៅកម្ពុជា ឬផ្សាយចេញពីឧបករណ៍ផ្សាយដែលមានទីតាំងនៅកម្ពុជា។

យ៉ាងណាមិញ សិទ្ធិអ្នកនិពន្ធស្នាដៃទទួលបានកិច្ចការពារ២ ប្រភេទ គឺសិទ្ធិបេតិកភណ្ឌ និងសិទ្ធិវប្បធម៌។ សិទ្ធិបេតិកភណ្ឌ គឺជាសិទ្ធិប្រកបអាជីវកម្មរបស់អ្នកនិពន្ធលើទ្រព្យជាស្នាដៃរបស់ខ្លួនតាមរយៈការផលិតឡើងវិញ ការផ្សាយជាសាធារណៈ និងការបង្កើតស្នាដៃបន្ត។ ដោយឡែក សិទ្ធិវប្បធម៌ មាន៣ចំណុច គឺអ្នកនិពន្ធមានសិទ្ធសម្រេចពីរបៀប និងការផ្សព្វផ្សាយជាសាធារណៈលើស្នាដៃរបស់ខ្លួន។ អ្នកនិពន្ធមានសិទ្ធិកំណត់ឱ្យគេទទួលស្គាល់ឈ្មោះ ឋានៈ និងស្នាដៃរបស់ខ្លួនសម្រាប់ទាក់ទងជាមួយ

សាធារណជន។ អ្នកនិពន្ធមានសិទ្ធិជំទាស់រាល់ការបំផ្លើស ឬ កែប្រែ និងកាត់ចោលខ្លឹមសារ ដែលធ្វើឱ្យប៉ះពាល់ដល់កិត្តិយសរបស់ខ្លួន។

សិទ្ធិសីលធម៌របស់អ្នកានិពន្ធ ជាសិទ្ធិអចិន្ត្រៃយ៍ មិនអាចលក់ដូរបាន មិនអាចរឹបអូសបាន និងមិនអាចផុតអាយុកាល។ ដូច្នេះ អ្នកនិពន្ធ ក៏ដូចជាបុគ្គលដែលបានបង្កើតស្នាដៃខ្លួនឯង គួរចុះឈ្មោះធ្វើកម្មសិទ្ធិបញ្ញាផ្ទាល់ខ្លួន ចៀសវាងអ្នកដទៃលួចស្នាដៃរបស់ខ្លួន៕

# ជំពូកទី៣ វិធានការនៃអំពើល្មើសចំពោះកម្មសិទ្ធិបញ្ញា

## ៣.១. សារៈសំខាន់នៃការពង្រឹងការការពារកម្មសិទ្ធិបញ្ញា

កម្មវត្ថុសំខាន់នៃការទទួលបាននូវកិច្ចការពារកម្មសិទ្ធិបញ្ញាគឺ ការផ្តល់លទ្ធភាពឱ្យសហគ្រាសធុនតូច និង មធ្យមរបស់អស់ លោកអ្នកទទួលបានផលជាផ្លែផ្កាពីតក្កកម្ម របស់និយោជិកដែលហុចផលជាកម្មសិទ្ធិបញ្ញា សម្រាប់សហគ្រាសធុនតូច និង មធ្យមរបស់អស់លោកអ្នក ។ ទ្រព្យសម្បត្តិខាងកម្មសិទ្ធបញ្ញានេះ គ្រាន់តែអាចនាំផ្លូវឆ្ពោះទៅរកអត្ថប្រយោជន៍ នៅពេលដែល កម្មសិទ្ធិបញ្ញានេះត្រូវបានគេការពារ បើពុំដូច្នេះទេជនល្មើស និងអ្នកផលិតទំនិញក្លែងក្លាយ ជានិច្ចកាលនឹងឆក់យកអត្ថប្រយោជន៍ ពីអវត្តមាននៃយន្តការពង្រឹងការការពារប្រកបដោយប្រសិទ្ធិភាព ដើម្បីឱ្យបានទទួលផលប្រយោជន៍ពីការងារដ៏លំបាករបស់អ្នក ។

ការទទួលបាន និងការរក្សាសិទ្ធិកម្មសិទ្ធិបញ្ញា អាចក្លាយទៅជាកិច្ចប្រឹងប្រែងដែលគ្មានន័យអ្វីទាំងអស់ប្រសិនបើសិទ្ធិនេះ ពុំត្រូវបានគេ ការពារពង្រឹកនៅក្នុងទីផ្សារទេ ។ នេះគឺជាការគំរាមកំហែងមួយនៃការពង្រឹងការការពារកម្មសិទ្ធិបញ្ញា ដែលអនុញ្ញាតឱ្យកម្មសិទ្ធិ ខាងបញ្ញាមួយអាចបានត្រូវធ្វើអាជីវកម្ម ក្រោមរូបភាពជាសម្បត្តិខាងពាណិជ្ជកម្ម ។ ប្រសិនបើយើងពិនិត្យនៅក្នុងបរិបទនេះ អត្ថិភាពនៃ របបការពារកម្មសិទ្ធិបញ្ញាប្រកបដោយប្រសិទ្ធភាពបានក្លាយទៅជាទិដ្ឋភាពរួមមួយនៃប្រពន្ធ័កម្មសិទ្ធិបញ្ញាដែលមានដំណើរការល្អប្រពៃ ។

ការពង្រឹងការការពារកម្មសិទ្ធិបញ្ញាមានសារៈសំខាន់ដើម្បី :

- រក្សានូវសុពលភាពស្របច្បាប់នៃកម្មសិទ្ធិបញ្ញាចំពោះមុខអាជ្ញាធរសារធារណៈដែលពាក់ព័ន្ធ ។
- ការពាររារាំងមិនអោយមានអំពើល្មើសបំពានកើតឡើង ឬបន្តកើតឡើងនៅក្នុងទីផ្សារដើម្បីបញ្ចៀសនូវការខូចខាត ដែលរួម មាននូវការខាតបង់វ័ត្តឈ្មោះពាណិជ្ជកម្ម ឬវ័ត្តឈ្មោះល្បីដទៃទៀត ។
- ស្វែងរកសំណងចំពោះការខូចខាតជាក់ស្តែងដូចជាការខាតបង់ប្រាក់ចំណេញដែលបណ្តាលមកពីអំពើល្មើសជាក់ស្តែងនៅ ទីផ្សារ ។

បន្ទុកនៃការពង្រឹងការការពារកម្មសិទ្ធិបញ្ញា ត្រូវធ្លាក់ជាពិសេសទៅលើអ្នកកាន់កាប់សិទ្ធិនោះ។ ប្រការនេះ អាស្រ័យទៅ លើអ្នកកាន់កាប់សិទ្ធិក្នុងការចង្អុលបង្ហាញនូវរាល់អំពើក្លែងបន្លំ ចំពោះកម្មសិទ្ធិបញ្ញា ហើយសម្រេចប្រកាន់យកវិធានការណា មួយសំរាប់ទប់ទល់ ។ ទោះជាស្ទើរតែគ្រប់ករណី ម្ចាស់សិទ្ធិតែងប្រកាន់យកនូវវិធានការបណ្តឹងរដ្ឋប្បវេណីក្តី ក៏ប៉ុន្តែក្នុងករណី ដែលមានការក្លែងបន្លំកម្មសិទ្ធិបញ្ញា និង

ការរំលោភសិទ្ធិអ្នកនិពន្ធ អស់លោកអ្នកអាចនឹងពិចារណាប្រកាន់យកវិធានការបណ្តឹង ព្រហ្មទណ្ឌ ប្រសិនបើជំរើសនេះ មានអាចជ្រើសយកបាន ។

ទោះជាយ៉ាងនេះក្តី បញ្ហានេះគឺជាការទទួលខុសត្រូវរបស់រដ្ឋាភិបាលនៃប្រទេសមួយ ឬរដ្ឋមួយក្នុងការបង្កើតឡើង នូវ ស្ថាប័នដែលសម្រួលដល់ការពង្រឹងការកាពារកម្មសិទ្ធិបញ្ញា ។ អង្គភាពតុលាការ និងក្នុងករណីខ្លះគឺអង្គភាពរដ្ឋាភិបាល ដូចជា ការិយាល័យកម្មសិទ្ធិបញ្ញា ឬអាជ្ញាធរគយ សុទ្ធតែជាស្ថាប័នរដ្ឋាភិបាលដែលអាចដោះស្រាយចំពោះករណីរំលោភបំពាន ឬ ករណី ក្លែងបន្លំកម្មសិទ្ធិបញ្ញានេះ ។ នៅពេលដែលគេជ្រើសរើសអនុវត្តវិធានការតាមព្រំដែន ដើម្បីការពារការនាំចូលទំនិញក្លែងបន្លំពាណិជ្ជសញ្ញា ឬទំនិញលួចថតចម្លងបំពានសិទ្ធិអ្នកនិពន្ធ អាជ្ញាធរគយមានតួនាទីសំខាន់មួយ ក្នុងការពង្រឹងការការពារកម្មសិទ្ធិ បញ្ញានៅតាមព្រំដែនអន្តរជាតិនៃប្រទេសមួយ ។ យោងទៅតាមបទប្បញ្ញតិទាំងឡាយនៃច្បាប់ដែលអាចអនុវត្តបាន អាជ្ញាធរគយ ត្រូវប្រកាន់យកសកម្មភាព តាមគំនិតផ្តួចផ្តើមដោយខ្លួនឯង និង តាមសំណើររបស់ម្ចាស់សិទ្ធិ ឬត្រូវអនុវត្តដីការរបស់តុលាការ ។ ជាងនេះទៅទៀត នៅក្នុងប្រទេសខ្លះមានសហគមឧស្សាហកម្មមួយចំនួន ដែលផ្តល់ការជួយគាំពារដល់សមាជិករបស់ខ្លួន ក្នុងការ ពង្រឹងការការពារកម្មសិទ្ធិបញ្ញារបស់ពួកគេ ។

ក្រៅពីនេះនៅមានជំរើសផ្សេងទៀត អាជ្ញាកណ្តាល មជ្ឈត្តករឯកជនដែលមានចែងនៅក្នុងកិច្ចសន្យារបស់លោកអ្នក ដោយផ្តល់លទ្ធភាពឱ្យមានការដោះស្រាយ វិវាទតាមមធ្យោបាយនេះ ។ ក្នុងការស្វែងរកការការពារកម្មសិទ្ធិបញ្ញារវាងភាគីទាំងឡាយដែលត្រូវអនុវត្ត ដោយ

## ៣.២. និតិវិធីជាធរមាននៃការពង្រឹងការការពារកម្មសិទ្ធិបញ្ញា

កិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទិននឹងសិទ្ធិកម្មសិទ្ធិបញ្ញា(កិច្ចព្រមព្រៀង TRIPS) តម្រូវឱ្យប្រទេសជា សមាជិកទាំងអស់នៃអង្គការពាណិជ្ជកម្មពិភពលោក (រួមទាំងប្រទេសដែលមានឧស្សាហកម្មជឿនលឿន និង ប្រទេសកំពុង អភិវឌ្ឍន៍ជាច្រើន) ផ្តល់នូវយន្តការដែលបានរៀបចំរួចដើម្បីពង្រឹងការការពារកម្មសិទ្ធិបញ្ញា។ បទប្បញ្ញត្តិពាក់ព័ន្ធទាំងឡាយនៃ កិច្ចព្រមព្រៀង TRIPS ធ្វើឡើង ដើម្បីស្វះស្វែងធានាធ្វើយ៉ាងណាឱ្យ និតិវិធីរដ្ឋប្បវេណី និតិវិធីរដ្ឋបាល និងនីតិវិធីព្រហ្មទណ្ឌព្រម ទាំងដំណោះស្រាយដទៃទៀត ចាំបាច់ត្រូវឆ្លើយតបទៅនឹងបទដ្ឋានអប្បបរមា ដែលបានចែងទាក់ទងទៅនឹងភស្តុតាង និងភាពអាច រកបាននៃអធិបញ្ញា ការខូចខាត ដំណោះស្រាយផ្សេងទៀត សិទ្ធិនៃការផ្តល់ព័ត៌មាន ការទទួលខុសត្រូវរបស់ដើមចោទ ក្នុង ការផ្តល់សំណង ទៅឱ្យចុងចោទ និង នីតិវិធីរដ្ឋបាល ។

ចំពោះម្ចាស់សិទ្ធិកម្មសិទ្ធិបញ្ញា ប្រការសំខាន់ចាំបាច់បំផុតដែលត្រូវដឹងនៅក្នុងភាពជាក់ស្តែងគឺ អាជ្ញាធរតុលាការនៅក្នុង ប្រទេសមួយចំនួនធំ បានទទួលសិទ្ធិអំណាចឱ្យចេញបញ្ជាជាបន្ទាន់ និងចាត់វិធានការបណ្តោះអាសន្ន ប្រកបដោយប្រសិទ្ធិភាព សំដៅបញ្ឈប់រាល់ការប៉ុនប៉ងប្រព្រឹត្តអំពើល្មើសបំពានសិទ្ធិកម្មសិទ្ធិបញ្ញាផ្សេង ។

ម្ចាស់សិទ្ធិកម្មសិទ្ធិបញ្ញានៅក្នុងប្រទេសមួយចំនួន អាចប្រើប្រាស់ផងដែរនូវវិធានការតាមព្រំដែនមួយចំនួន ដើម្បីការពារ រារាំងនូវការនាំចូលទំនិញក្លែងបន្លំពាណិជ្ជសញ្ញា និង ទំនិញថតចម្លងបំពានសិទ្ធិអ្នកនិពន្ធ (នៅតាមព្រំដែនអន្តរជាតិ) តាមរយៈ អាជ្ញាធរគយជាតិរបស់ប្រទេសទាំងនោះ ។ ក្នុងនាមជាម្ចាស់សិទ្ធិកម្មសិទ្ធិបញ្ញាមួយរូប អស់លោកអ្នក អាចទទួលបាននូវការជួយ ឧបត្ថម្ភពីអាជ្ញាធរគយនៅតាមព្រំដែន ព្រោះថាបើពុំដូច្នេះទេ លោកអ្នកនឹងត្រូវដោះស្រាយជាមួយជនល្មើសបំពានជាច្រើន ថែម ទៀតនៅពេល ដែលទំនិញល្មើសទាំងនោះត្រូវបានគេចែកចាយនៅក្នុងប្រទេស ។

## ៣.៣. ពង្រឹងការការពារកម្មសិទ្ធិបញ្ញា

អ្វីដែលមានសារប្រយោជន៍ និង ចាំបាច់បំផុតនោះ គឺការស្វែងរកដំបូន្មានពីអ្នកជំនាញការ នៅពេលដែលម្ចាស់សិទ្ធិ កម្មសិទ្ធិបញ្ញាយល់ឃើញថា មានអ្នកណាម្នាក់កំពុងរំលោភបំពានសិទ្ធិរបស់ខ្លួន ។

ដើម្បីចៀសវាងការជំពាក់ជាក់រឹនទៅនឹងបញ្ហាហិរញ្ញវត្ថុ និង ធនធានមនុស្ស នៅក្នុងដំណើរការក្តីធម្មតាមួយ នៅពេលណាដែល ម្ចាស់សិទ្ធិកម្មសិទ្ធិបញ្ញា រកឃើញថាមានអ្នកណាម្នាក់កំពុងរំលោភបំពានសិទ្ធិរបស់ខ្លួន ជាដំបូងគាត់ត្រូវគិតគូរ អំពីការផ្ញើ រលិខិតមួយច្បាប់ (ជាធម្មតាត្រូវគេស្គាល់ថា ជាលិខិតស្នើសុំឱ្យបញ្ឈប់លែងធ្វើសកម្មភាពបំពាន) ទៅឱ្យជនល្មើស ដើម្បីជូនដំណឹងឱ្យបុគ្គលនោះដឹងអំពីលទ្ធភាពដែលអាចកើតមានឡើង នូវវិវាទរវាងសិទ្ធិកម្មសិទ្ធិបញ្ញានៃសហគ្រាស របស់ខ្លួន និងសកម្មភាពអាជីវកម្មរបស់ជនល្មើស (ត្រូវបង្ហាញឱ្យច្បាស់នូវចំនុចនៃវិវាទនេះ) រួចស្នើឡើងនូវដំណោះស្រាយ ដែលអាចធ្វើទៅបានមួយចំពោះបញ្ហា ដែលត្រូវលើកយក មកពិភាក្សានេះ ។

គេត្រូវចាំបាច់ស្វែងរកជំនួយពីមេធាវី នៅពេលដែលសរសេរសំបុត្រស្នើសុំឱ្យបញ្ឈប់លែងប្រព្រឹត្តអំពើល្មើសបំពាននេះ ដើម្បីចៀស វាងកុំឱ្យមានដំណើរការខាងផ្លូវតុលាការ ដែលផ្តើមឡើងដោយជនល្មើសក្នុងការតបតថា គ្មានអំពើរំលោភបំពានណាមួយបានកើត ឡើង ឬកំពុងតែកើតឡើងទេ ។ និតិវិធីនេះជារឿយៗតែងមានប្រសិទ្ធភាពក្នុងករណីនៃបទល្មើសដោយអចេតនាដោយហេតុថា ជនល្មើសនៅក្នុងករណីជាច្រើន នឹងបញ្ឈប់សកម្មភាពរបស់ខ្លួនឬយល់ព្រមធ្វើការចរចាឱ្យមានកិច្ចសន្យាអាជ្ញាបណ្ណមួយ ។

នៅពេលដែលប្រឈមមុខនឹងបទល្មើសដោយចេតនា ជាពិសេសរួមទាំងការក្លែងបន្លំទំនិញ និង ការបំពានសិទ្ធិអ្នកនិពន្ធ លោកអ្នកត្រូវតែស្វែងរកជំនួយពីអាជ្ញាធរអនុវត្តច្បាប់ ដើម្បីពញ្ញាក់ស្មារតីរបស់ជនល្មើសនោះ នៅក្នុងបរិវេលាអាជីវកម្មរបស់គេ ការពារកុំឱ្យមានអំពើល្មើសតទៅទៀត និង ដើម្បីរក្សាភស្តុតាងពាក់ពន្ធ័នឹងអំពើល្មើសនោះ ។ ជាងនេះទៅទៀត ជនល្មើសអាច ត្រូវបានបង្ខំដោយតុលាការមានសមត្ថកិច្ច ឱ្យធ្វើការជូនដំណឹងដល់ម្ចាស់សិទ្ធិអំពីអត្តសញ្ញាណរបស់ជនទី ៣ ដែលពាក់ព័ន្ធក្នុង ការ ផលិត និង ចែកចាយទំនិញ ឬសេវាបំពានកម្មសិទ្ធិបញ្ញា ព្រមទាំងខ្សែរយៈនៃការចែកចាយនោះផង ។ ក្នុងនាមជាស្ថាប័ន ដែលផ្តល់ការរារាំងប្រកបដោយប្រសិទ្ធិភាពចំពោះអំពើបំពានកម្មសិទ្ធិបញ្ញា អាជ្ញាធរតុលាការអាចចេញបញ្ជា នៅពេលដែលមាន សំណូមពរពីម្ចាស់សិទ្ធិឱ្យធ្វើការបំផ្លាញចោល ចាំបាច់ត្រូវចេញសំណងអ្វីឡើយ ។ ឬដាក់អោយទំនិញដែលបំពានកម្មសិទ្ធិបញ្ញាស្ថិតនៅក្រៅចរន្តពាណិជ្ជកម្ម ដោយគ្មាន

ប្រសិនបើលោកអ្នកពិចារណា ដោយគិតពីអត្ថប្រយោជន៍របស់ខ្លួន ដោយចៀសវាងដំណើរការក្តីតាមផ្លូវតុលាការ លោក អ្នក អាចពិចារណាពីការប្រើប្រាស់យន្តការដោះស្រាយវិវាទផ្សេងទៀត ដូចជាការប្រើប្រាស់អាជ្ញាកណ្តាល ឬ ការផ្សះផ្សាជាដើម។

## ៣.៤. ការអនុវត្តន៍ច្បាប់ ភាតព្វកិច្ចទូទៅនៅប្រទេសកម្ពុជា

វិធានការនានាបច្ចុប្បន្នសម្រាប់បង្រ្កាបការរំលោភសិទ្ធិកម្មសិទ្ធិបញ្ញាមានមូលដ្ឋានផ្អែកទៅលើបទប្បញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ ព្រហ្មទ័ណ្ឌ និង នីតិវិធីព្រហ្មទណ្ឌ សម្រាប់អនុវត្តនៅក្នុងប្រទេសកម្ពុជានាសម័យអន្តរកាល ចុះថ្ងៃទី ១០ កញ្ញា ១៩៩២ ព្រមទាំង សេចក្តីប្រកាសលេខ ៣៦៨ ចុះថ្ងៃទី ១៥ ធ្នូ ១៩៩៧ ស្តីពី វិធានការនានា សំរាប់បង្រ្កាបការរំលោភសិទ្ធិ កម្មសិទ្ធិ បញ្ញានៅក្នុង ប្រទេសកម្ពុជា ។ ជាបន្ថែមច្បាប់ថ្មី ដូចជា ច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, ច្បាប់ស្តីពីសិទ្ធិ អ្នកនិពន្ធ និង សិទ្ធិប្រហាក់ប្រហែល ព្រមទាំងច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថ ប្រយោជន៍ និងគំនូរ ឧស្សាហកម្ម មានបទប្បញ្ញត្តិទាក់ទងទៅនឹងការខកខានមិនបានបំពេញករណីកិច្ច ដូចជា ការខកខានមិនបាន បង់ប្រាក់ឈ្នួលសំរាប់ រក្សា ឬការខកខានមិនបានប្រើពាណិជ្ជនាម ឬប្រកាសនីយបត្រតក្កកម្មដែលបានចុះបញ្ជីក្នុងរយៈពេលដែលច្បាប់បានកំណត់ អាចនាំ ទៅរកមោឃភាពនៃការការពារ ឬ ការផ្តល់អាជ្ញាប័ណ្ណឱ្យដល់ភាគីទី ៣ ឬ អង្គភាពរដ្ឋបាល ដោយមានទស្សនៈសម្រាប់ផ្គត់ផ្គង់ ដល់ទីផ្សារក្នុងស្រុក ។

សេចក្តីព្រាងច្បាប់របស់ប្រទេសកម្ពុជាស្តីពីសិទ្ធិកម្មសិទ្ធិបញ្ញា ស្របទាំងស្រុងជាមួយនឹងមាត្រាទី ៤១ នៃកិច្ចព្រមព្រៀង TRIPS ដែលមានចែងពីនីតិវិធី ការដាក់ឱ្យអនុវត្តទៅតាមច្បាប់ក្នុងស្រុក អត្ថិភាពនៃ

នីតិវិធីប្រកបដោយភាពត្រឹមត្រូវ និង ដ៏យុត្តិធម៌ និង ឱកាសសំរាប់ភាគីនានាធ្វើការប្ដឹងផ្ដល់ទាមទារឱ្យពិនិត្យឡើងវិញនូវសេចក្ដីសម្រេចផ្នែករដ្ឋបាល និង សេចក្ដីសម្រេច ពីដំបូង របស់តុលាការ ដែលធ្វើឡើងដោយអាជ្ញាធរតុលាការ ។

## ៣.៤.១. នីតិវិធីរដ្ឋប្បវេណី របស់តុលាការ និង ឧបបាស្រ័យ

បទបញ្ញត្តិស្ដីពីនីតិវិធីតុលាការ និងឧបប្រាស្រ័យត្រូវបានដាក់បញ្ចូលនៅក្នុងសេចក្ដីព្រាងក្រមរដ្ឋប្បវេណី សេចក្ដីព្រាងក្រមនីតិ វិធីរដ្ឋប្បវេណី និង សេចក្ដីព្រាងច្បាប់ស្ដីពីកម្មសិទ្ធិបញ្ញាមួយចំនួនដែលបច្ចុប្បន្នកំពុងស្ថិតនៅក្នុងការរៀបចំ ។ បទបញ្ញាសំរាប់ អនុវត្តច្បាប់ និងក្រមទាំងនេះគឺឋិតនៅក្នុងការពិចារណានៅឡើយ ។ ក្រមរដ្ឋប្បវេណីនឹងមានដាក់បញ្ចូលនូវនីតិវិធីដែល ទាក់ទិន នឹងការវិនិច្ឆ័យរដ្ឋប្បវេណីការប្រតិបត្តិ និងវិធានការបណ្ដោះអាសន្ននានាហើយច្បាប់ស្ដីពីកម្មសិទ្ធិបញ្ញានឹងមានចែងនូវបទប្ប ញ្ញត្តិនានាសំរាប់ឧបាស្រ័យ និង វិធានការដោះស្រាយជាបណ្ដោះអាសន្ន ។ អាជ្ញាធរអនុវត្តច្បាប់ រួមមានតុលាការ ទីចាត់ការគយ និងរដ្ឋាករក៏ដូចជា CAMCONTROL ដែលជាអង្គភាពមួយឋិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងពាណិជ្ជកម្ម និងប៉ូលីស សេដ្ឋកិច្ច។ អង្គភាពទាំងពីរចុងក្រោយនេះ ទទួលខុសត្រូវបង្ក្រាបនូវការបន្លំបោក និងត្រួតពិនិត្យមើលទំនិញនាំចូល និង នាំចេញ ។

យោងតាមបទបញ្ញាថ្មី តុលាការ រាប់ទាំងតុលាការខេត្ត ក្រុងមានសិទ្ធិអំណាចដោះស្រាយនូវរាល់ការរំលោភបំពានសិទ្ធិកម្ម សិទ្ធិបញ្ញា ជម្លោះពីរឿងប្រាក់ទូទាត់លើការប្រើសិទ្ធិកម្មសិទ្ធិបញ្ញានិងប្រាក់បំណាច់ ការរំលោភបំពានសិទ្ធិអ្នកនិពន្ធ ព្រម ទាំងសិទ្ធិសំរាប់ដាក់ពាក្យសុំ និង ជម្លោះដែលទាក់ទិនទៅនឹងការផ្ទេរ ព្រមទាំងការផ្ដល់អាជ្ញាប័ណ្ណប្រគលសិទ្ធិជាផ្លូវការផងដែរ ។ ភាគីដែល រងគ្រោះ អាចស្នើសុំអធិបញ្ញារបស់តុលាការ ដើម្បីបញ្ចប់ការបំពាន ហើយទាមទារការទូទាត់ ចំពោះការខូចខាត ។

ចំនួនទឹកប្រាក់សំរាប់ការខូចខាត ត្រូវបានគិតគូរដោយឈរលើមូលដ្ឋានករណីនីមួយៗ ។ ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ចែងពីការប្រគល់សិទ្ធិអំណាចតាមផ្លូវច្បាប់ឱ្យតុលាការចេញសេចក្ដីសម្រេចសងការខូចខាត សម្រេចផ្ដល់នូវចំនួនទឹកប្រាក់ជម្ងឺចិត្ត ចំពោះការខូចខាត និង វិធានការដោះស្រាយផ្សេងទេ ទោះជាគ្មានបទបញ្ញត្តិលំអិតក៏ដោយ ។

តុលាការមានអំណាច ចេញដីកាបង្គាប់ឱ្យផ្ដល់ឯកសារទាំងនោះ (មាត្រា១៥២ នៃសេចក្ដីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី) ហើយការខកខានមិនបានផ្ដល់ អាចនាំឱ្យតុលាការទទួលស្គាល់ថា សេចក្ដីអះអាងរបស់ភាគីម្ខាងទៀតដែលពាក់ព័ន្ធនឹងសេចក្ដីថ្លែង ការណ៍ក្នុងឯកសារនោះ ជាការពិតបាន (មាត្រា ១៥៣)

ហើយអាចធ្វើការផ្អាកពិន័យដែលខកខាន មិនបានផ្តល់ឯកសារនោះ (មាត្រា ១៥៤)។ ឯព័ត៌មានសំងាត់ត្រូវបានការពារទៅតាមមាត្រា ៤២ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និង អំពើនៃការប្រកួត ប្រជែងមិនស្មោះត្រង់ និង មាត្រា ១២៨ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរ ឧស្សាហកម្ម ។ បទប្បញ្ញត្តិទូទៅដែលយោងទៅលើច្បាប់ជាក់លាក់ ត្រូវបានដាក់បញ្ចូលនៅក្នុងមាត្រា ១១៥,១ នៃសេចក្តីព្រាង ក្រមនីតិវិធីរដ្ឋប្បវេណី ។

## ៣.៤.២. វិធានការបណ្តោះអាសន្ន

អាជ្ញាធរ និងតុលាការដែលទទួលខុសត្រូវចំពោះការគ្រប់គ្រងអនុវត្តច្បាប់ស្តីពីសិទ្ធិកម្មសិទ្ធិបញ្ញាមានអំណាចចេញបញ្ជាឱ្យ អនុវត្តវិធានការបណ្តោះអាសន្នភ្លាមៗ និង មានប្រសិទ្ធិភាព ដោយឈរលើភស្តុតាងជាក់ស្តែង ដើម្បីរារាំងដល់ការរំលោភបំពាន និង រក្សាទុកនូវភស្តុតាងដែលពាក់ព័ន្ធ។ យោងតាមមាត្រា ៣០ (ក)នៃច្បាប់ស្តីពីម៉ាកពាណិជ្ជនាមនិងអំពើនៃការប្រកួតប្រជែង មិនស្មោះត្រង់ មានចែងពីភស្តុតាងជាក់ស្តែងដែលមានមូលដ្ឋានសមហេតុផលដើម្បីធ្វើឱ្យជឿថាការរំលោភបំពានមួយកំពុងកើត មានឡើងហើយ ។ វិធានការបណ្តោះអាសន្នដែលអាចអនុវត្តបាន រួមមាន ការឃាត់ទុកនូវភស្តុតាងដែលពាក់ព័ន្ធនិងវត្ថុប្រើ ប្រាស់ ការស្រាវជ្រាវរកវត្ថុប្រើប្រាស់ និងសំភារៈលាប់បំពួន បញ្ជាឱ្យបញ្ឈប់នូវការរំលោភបំពានការរិបអូសយករបស់ ឬទំនិញ ដែលគេ រំលោភបំពាន និងការរឹបអូសយកជាបណ្តោះអាសន្ននូវទំនិញនានាដើម្បីធានាឱ្យមានការទូទាត់សំណងត្រឹមត្រូវ ជាមុនសិន ។

## ៣.៤.៣. នីតិវិធីរដ្ឋបាល និង ឧបប្រាស្រ័យ

តាមបទបញ្ជាថ្មី អាជ្ញាធរមានសមត្ថកិច្ចដែលអនុវត្តវិធានការរដ្ឋបាល និងបាស្រ័យនោះ គឺក្រសួងពាណិជ្ជកម្ម, ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ព្រមទាំងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ទីចាត់ការគយនិងរដ្ឋាករ និង ប៉ូលីសសេដ្ឋកិច្ច ។ វិធានការផ្នែករដ្ឋបាល និងបាស្រ័យរាប់បញ្ចូលទាំងការព្រមាន ការពិន័យជាប្រាក់រហូតដល់ ២៥លានរៀល (ប្រមាណជា US$ ៦០០០) ការរឹបអូស យកសំភារៈ និងវត្ថុប្រើប្រាស់ការបំផ្លាញទំនិញដែលរំលោភបំពាន និងការទូទាត់សងជម្ងឺចិត្ត។ យោងតាមច្បាប់ស្តីពីម៉ាកពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ព្រមទាំងច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលនោះ អាជ្ញាធរ មានសមត្ថកិច្ចមានអំណាចចេញអធិបញ្ជា ដើម្បីបង្គាប់ឱ្យភាគីមួយ បញ្ឈប់នូវការរំលោភបំពាន និង ឃាត់ទុកជាបណ្តោះអាសន្ន នូវការជំរះបញ្ជីគយដើម្បីនាំទំនិញដែលរំលោភកម្មសិទ្ធិបញ្ញាចូល ដូចដែលចែងនៅក្នុងមាត្រា ៤៤,១ នៃកិច្ចព្រមព្រៀង TRIPS ក៏ប៉ុន្តែមិនមានអំណាចចេញបញ្ជាឱ្យជនល្មើសផ្តល់ព័ត៌មានដល់អ្នកកាន់កាប់សិទ្ធិ អំពីតតិយជន ដែលពាក់ព័ន្ធនៅក្នុងការផលិត និង

ចែកចាយទំនិញដែលបំពាននោះបានឡើយ ។ ទោះជាយ៉ាងណាក៏ដោយ ក៏ពួកគេអាចរកបានព័ត៌មានបែបនេះដោយខ្លួនឯងដែរ ។ ច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ (មាត្រា ៤៦) និងច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល(មាត្រា៥៩) បានហាមមិនឱ្យនាំទំនិញក្លែងបន្លំឬត្រូវបានចោរលួចចេញ ទៅវិញឡើយហើយបានប្រគល់ អំណាចដល់ទីចាត់ការគយ និង រដ្ឋាករ ព្រមទាំងអាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀត ឱ្យបំផ្លាញទំនិញបំពាននោះចោល ទៅតាមសេចក្តីសម្រេចរបស់តុលាការ ។ ទំនិញបំពាន មិនអាចបំផ្លាញចោល ដោយគ្មានបញ្ជាពីតុលាការ បានឡើយ ។

### ៣.៤.៤. វិធានការពិសេស តាមច្រកព្រំដែន

សេចក្តីព្រាងច្បាប់ស្តីពី គយ និងរដ្ឋាករ មិនបានដាក់បញ្ចូលនូវបទប្បញ្ញត្តិស្តីពីវិធានការតាមច្រកព្រំដែន ដូចដែលមាត្រា ពី ៥១ ដល់ ៦០ នៃកិច្ចព្រមព្រៀង TRIPS តម្រូវឱ្យមានឡើយ ។ វិធានការដែលចាំបាច់តាមច្រកព្រំដែន ត្រូវបានដាក់បញ្ចូល ទៅក្នុងច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ (មាត្រាពី ៣៥ ដល់ ៤៧)។ ជាបន្ថែមច្បាប់ ស្តីពីសិទ្ធិអ្នកនិពន្ធ និង សិទ្ធិប្រហាក់ប្រហែល (មាត្រា ៦៣) បានដាក់បញ្ចូល តាមរយៈឯកសារយោងនូវរាល់វិធានការ តាម ច្រកព្រំដែនទាំងអស់ ដែលមាននៅក្នុងច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ។ សេចក្តីច្បាប់ (មាត្រា ៨) តម្រូវយ៉ាងជាក់ច្បាស់ឱ្យអាជ្ញាធរគយ អនុវត្តច្បាប់ទាំងអស់របស់ប្រទេសកម្ពុជា ហើយបទប្បញ្ញត្តិនេះគាំទ្រដោយ អនុក្រឹត្យមួយដែលនឹងត្រូវរៀបចំឡើងដោយទីចាត់ការគយ និងរដ្ឋាករ ក្រោមកិច្ចសហប្រតិបត្តិការជាមួយក្រសួង ដែលទទួលខុស ត្រូវក្នុងការការពារសិទ្ធិកម្មសិទ្ធិបញ្ញា ។

ច្បាប់របស់ប្រទេសកម្ពុជា មានចែងអំពីការរឹបអូសការបាត់បង់សិទ្ធិព្រមទាំងការបំផ្លាញទំនិញ ភស្តុតាងឯកសារ ឬ វត្ថុចំលង ព្រមទាំងឧបករណ៍ដែលប្រើសំរាប់ផលិតទំនិញដែលបំពាន ដែលពាក់ព័ន្ធចោល, ហើយបានហាមប្រាមការនាំចេញទៅវិញ នូវទំនិញ ដែលប្រើពាណិនាមក្លែងបន្លំ ឬ ការប្រើនូវនីតិវិធីផ្សេងទៀតរបស់គយ ។ តាមបទបញ្ជាថ្មីអាជ្ញាធរគយត្រូវបានអនុញ្ញាតឱ្យផ្តល់ ព័ត៌មានអំពីលទ្ធភាពក្នុងការនាំចេញនាំចូលទំនិញ បំពានដល់អ្នកកាន់កាប់សិទ្ធិ ។ អ្នកកាន់កាប់សិទ្ធិអាចដាក់ពាក្យសុំទៅ អាជ្ញាធរ គយឱ្យផ្អាកការជំរះបញ្ជីគយលើទំនិញដែលសង្ស័យជាបណ្តោះអាសន្នសិនបាន ។ ពាក្យសុំនេះត្រូវមានការពិពណ៌នាយ៉ាងលំ អិតអំពីទំនិញនោះ ។ អាជ្ញាធរគយមានកាព្វកិច្ចផ្តល់ព័ត៌មានដល់អ្នកកាន់កាប់សិទ្ធិនូវរាល់វិធានការដែលបានធ្វើ,ហើយត្រូវលុប វិធានការនោះចោល បើសិនជាគ្មានបណ្តឹងក្នុងរយៈពេល១០ថ្ងៃ ។ អ្នកកាន់កាប់សិទ្ធិត្រូវទទួលខុសត្រូវចំពោះជម្ងឺចិត្តណាមួយ ដែលកើតចេញពីពាក្យសុំដែលគ្មានខ្លឹមសារ ។ ក្នុងករណីមានភស្តុតាងជាក់ស្តែងអាជ្ញាធរគយអាចផ្អាកការជំរះបញ្ជីគយលើទំនិញ ដែលសង្ស័យជាប

ណ្តោះអាសន្នបាន ទៅតាមការផ្តួចផ្តើមគំនិតរបស់ពួកគេ ហើយត្រូវផ្តល់ព័ត៌មានភ្លាមៗ ដល់អ្នកកាន់កាប់សិទ្ធិ នូវកាលបរិច្ឆេទ និងទីកន្លែងនៃការផ្អាកនោះ ។

### ៣.៤.៥. នីតិវិធីព្រហ្មទណ្ឌ

ការរំលោភបំពានលើសិទ្ធិកម្មសិទ្ធិបញ្ញា ត្រូវស្ថិតនៅក្រោមការចោទប្រកាន់ពីបទព្រហ្មទណ្ឌ ទៅតាមច្បាប់ស្តីពី ម៉ាក, ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ (មាត្រាពី ៦៣ ដល់ ៦៨) ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបន បត្រ័ម៉ូដែលមានអត្ថប្រយោជន៍ និង គំនូរឧស្សាហកម្ម (មាត្រា ១៣២ និង ១៣៣) ព្រមទាំងច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និង សិទ្ធិ ប្រហាក់ប្រហែល (មាត្រា ៦៤ និង ៦៥) ។ ករណីបទល្មើសព្រហ្មទណ្ឌ អាចផ្តន្ទាទោសបានដោយការពិន័យជាប្រាក់ រហូលដល់ទៅ ២៥លានរៀល (ប្រមាណជា US$ ៦០០០) ឬ ផ្តន្ទាទោសដាក់ពន្ធនាគារពី ០១ ខែ រហូតដល់ ០៦ខែ ។ ក្នុងករណីមិនរាងចាល ហើយបានប្រព្រឹត្តបទល្មើសនៅក្នុងរយៈពេល ៥ឆ្នាំ រាប់ចាប់ពីកាលបរិច្ឆេទនៃការផ្តន្ទាទោសលើកទី ១ មក ការផ្តន្ទាទោស នេះ អាចកើនឡើង មួយជាពីរ។ បទបញ្ញាសម្រាប់អនុវត្តច្បាប់ទាំងនេះ ត្រូវបញ្ជាក់ឱ្យច្បាស់អំពីកាលៈទេសៈនានា ដែលត្រូវចោទ ប្រកាន់ពីបទល្មើសព្រហ្មទ័ណ្ឌនេះ ។ ចំពោះការលក់ការចែកចាយ និងការនាំចូល ឱសថក្លែងក្លាយនោះ បទប្បញ្ញត្តិនៅក្នុងច្បាប់ ស្តីពីការគ្រប់គ្រងឱសថ អាចយកមកប្រើប្រាស់បាន ដើម្បីចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និង ដើម្បីការពារសិទ្ធិរបស់អ្នកកាន់កាប់សិទ្ធិ ផងដែរ ។

# សេចក្តីសន្និដ្ឋាន

កម្មសិទ្ធិបញ្ញា គឺជាប្រភេទសិទ្ធិដ៏សំខាន់មួយដែលត្រូវបានបង្កើតឡើងដើម្បីការពារស្នាដៃនៃការគិតច្នៃប្រឌិត និងការបង្កើតថ្មីរបស់មនុស្ស។ កម្មសិទ្ធិបញ្ញាមិនត្រឹមតែជាការការពារស្នាដៃបញ្ញាទេ ប៉ុន្តែថែមទាំងជាគ្រឹះសំខាន់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងវប្បធម៌នៅក្នុងសម័យទំនើប។ កម្មសិទ្ធិបញ្ញាត្រូវបានបែងចែកជាពីរប្រភេទសំខាន់ៗ គឺកម្មសិទ្ធិឧស្សាហកម្ម និងសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល។ ការការពារសិទ្ធិទាំងនេះមានគោលបំណងធានាថាអ្នកនិពន្ធ អ្នកសិល្បៈ និងអ្នកបង្កើតស្នាដៃអាចគ្រប់គ្រង និងប្រើប្រាស់ស្នាដៃរបស់ខ្លួនដោយស្របច្បាប់។ ប្រសិនបើគ្មានវិធានការច្បាប់សម្រាប់ទប់ស្កាត់ កម្មសិទ្ធិបញ្ញានឹងមានការរំលោភបំពាន ។ ដូច្នេះ ប្រទេសកម្ពុជាបានបង្កើតច្បាប់ និងនីតិវិធីផ្សេងៗដើម្បីការពារសិទ្ធិកម្មសិទ្ធិបញ្ញា។ វិធានការទាំងនោះអនុញ្ញាតឱ្យម្ចាស់សិទ្ធិអាចដាក់ពាក្យបណ្តឹង ទាមទារសំណង ឬស្នើឱ្យអាជ្ញាធរទប់ស្កាត់ការនាំចូល និងការចែកចាយទំនិញក្លែងក្លាយ។ ការអនុវត្តវិធានការទាំងនេះមិនត្រឹមតែការពារសិទ្ធិរបស់ម្ចាស់ស្នាដៃប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយធានាការប្រកួតប្រជែងយ៉ាងស្មោះត្រង់ក្នុងទីផ្សារផងដែរ។

ការយល់ដឹង និងការគោរពច្បាប់ស្តីពីកម្មសិទ្ធិបញ្ញា គឺមានសារៈសំខាន់ខ្លាំងសម្រាប់បុគ្គល ស្ថាប័ន និងសង្គមទាំងមូល។ មនុស្សគ្រប់រូបគួរតែមានការយល់ដឹងអំពីសិទ្ធិ និងកាតព្វកិច្ចដែលពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញា ដើម្បីការពារស្នាដៃរបស់ខ្លួន និងជៀសវាងការរំលោភសិទ្ធិរបស់អ្នកដទៃ។ ការពង្រឹងប្រព័ន្ធការពារកម្មសិទ្ធិបញ្ញា នឹងជួយលើកកម្ពស់ការបង្កើតថ្មី ការអភិវឌ្ឍវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងវប្បធម៌ ហើយនឹងរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមរបស់ប្រទេសជាតិ

# គន្ថនិទ្ទេស


- ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ២០០៣
- កម្មសិទ្ធិបញ្ញា ( https://www.scribd.com/document/ ) ដកស្រង់ថ្ងៃទី១០ មីនា ២០២៦
- គេហទំព័រកម្ពុជាថ្មីថ្មី ( https://www.kampucheathmey.com/local-news/ ) ដកស្រង់ថ្ងៃទី១០ មីនា ២០២៦
- ច្បាប់ស្តីពីកម្មសិទ្ធិបញ្ញា ( https://www.google.com/url?q=https://vannarachin.wordpress.com/ ) ដកស្រង់ថ្ងៃទី១០ មីនា ២០២៦